

# MONTHLY REPORT

## VOLUME 49
## JANUARY 2026

**CONTACT INFORMATION**

Email: info@jicastrings.com

Project Office:
- Ministry of Health (MoH)

Department of Human Resources Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh
- National Maternal and Child Health Center (NMCHC)

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

Scan here to find out more about us:
JICA's FB Page
Project's Homepage

## PROJECT ACTIVITIES IN JANUARY :

- 8th : Trainer meeting for Quality Improvement and Patient Safety (Online)
- 9th : Monthly Meeting with JICA HQ / Cambodia Office (Online)
- 14th–15th : INSET in KC (Quality Improvement and Patient Safety & Basic Nursing Skills)
- 21st–22nd : INSET in KC (Nursing Research)
- 22nd : ToT Nationwide Coordination Meeting
- 26th : IT Short-term Expert Joined the Team
- 27th : ELP Meeting with HRDD IT team
- 28th–29th : INSET in KC (Nursing Process Application & Nursing Informatics)
- 30th : Completion of internship (Nagasaki University MPH student)

## Nationwide Expansion of INSET: Strategic Meeting for ToT implementation

On 22 January, 2026, the Human Resources Development Department (HRDD) led a pivotal nationwide meeting at the MoH to discuss scaling up the INSET program across all 25 municipal and Provincial Health Administrations. Chaired by H.E. Prof. THIR Kruy, Secretary of State and Project Director, the session convened MoH and PHD stakeholders, with the STRINGS project team attending as observers to move forward the 2026 national roadmap.

A central focus was the nationwide rollout of the National Training of Trainers (N-ToT) for Nursing Ethics, selected for its importance to professional standards. Asst. Prof. Dr. TOUCH Sokneang, Project Manager, outlined an implementation strategy leveraging experiences from pilot provinces. The N-ToT sessions are tentatively scheduled between April and August 2026 across five regions, including Phnom Penh. These sessions will develop a core group of trainers who will lead subsequent sessions within their provinces to ensure patient-centered care.

The meeting facilitated a productive exchange where Battambang (BTB) and Kampong Cham (KC) representatives shared lessons from In-service Training (INSET) implementation. Participants highlighted essential criteria for nominating committed trainers to ensure training quality. Furthermore, they explored sustainability, focusing on the necessity for provinces to integrate the INSET into official annual operational plans to sustain trainings after the project ends.



Nursing Ethics Module



Meeting Participants

## First 2026 INSET in Kampong Cham: Empowering Trainers and Trainees

Continuing the momentum from last year, the first INSET sessions for 2026 were successfully launched in KC. On 14-15 January, the program commenced with 30 participants attending the Quality Improvement & Patient Safety (QI & PS) course and 31 participants joining the Basic Nursing Skills (BNS) course. This significant occasion was attended by Asst. Prof. Dr. KOY Virya, Deputy Director of the Hospital Service Department at the MoH and Chair of the National Training Management Team (TMT), alongside Mr. CHEA Sopheakmoniroth, President of the Cambodian Council of Nurses, who both served as supervisors.

The training began with opening remarks from the two visiting supervisors and H.E. Dr. KIMSOUR Phirun, Director of KC Provincial Health Department (PHD). Their speeches highlighted the vital importance of this training and set high expectations for the enhancement of participants' skills and the strengthening of nursing care quality. Following their remarks, the supervisors observed the sessions and provided valuable inputs to PTMT members, trainers, and trainees to further refine the INSET implementation. They specifically encouraged trainers to maintain their dedicated efforts in delivering high-quality lectures. Additionally, a coordination meeting held on the same day allowed supervisors, the project team, and PHD representatives to share supervision findings and discuss challenges and responsibilities for the upcoming stage.

The following week, the training continued with the Nursing Research course for 22 participants on 21-22 January, followed by the Nursing Informatics course for 23 participants and the Nursing Process Application course for 33 participants on 28-29 January.

Looking ahead to February, several courses are scheduled across three Operational Districts in KC and BTB. These activities are expected to cover the remaining 20% of target trainees, contributing significantly to the achievement of the project's training target populations.



Opening Session



BNS course



# MONTHLY REPORT

VOLUME 49

JANUARY 2026


**CONTACT INFORMATION**

Email: info@jicastrings.com

Project Office:
- Ministry of Health (MoH)

Department of Human Resources Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh
- National Maternal and Child Health Center (NMCHC)

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage

## Expert Mission: Accelerate the Enhancement of the E-Learning Platform

On 26 January, 2026, Mr. ONO Tsutomu, a Short-term Expert in Training System Development and Management, commenced his first one-month mission in Cambodia. Since his arrival, he has proactively engaged with key stakeholders to streamline the E-Learning Platform (ELP).

During his first week, Mr. ONO hit the ground running with the following activities:

- Strategic Consultation with HRDD: On 27 January, he met with the HRDD IT team to review the mission's work plan and discuss the way forward for the ELP. A follow-up meeting is scheduled for 10 February to conduct a demonstration of potential system options, which will help finalize the strategic direction for the ELP enhancement.
- Field Insight in KC Province: On 28 January, he observed a Nursing Informatics course in KC. This visit allowed for direct dialogue with the PTMT and IT technicians regarding on-site operational needs.
- Knowledge Sharing with NMCHC: On 30 January, he consulted with IT officers at the National Maternal and Child Health Center (NMCHC), gaining valuable insights from their existing ELP operations as a benchmark for the project.

In just one week, Mr. ONO has demonstrated a sharp understanding of the ELP's core issues. By synthesizing information through energetic field visits and stakeholder consultations, he is ensuring a smooth transition from assessment to implementation. His first mission continues until 23 February, and we are confident his expertise will significantly strengthen our training management system.





Meeting with HRDD IT team



Training Observation in KC



## Welcoming a New Expert and Farewell to Our Intern



We are pleased to welcome Mr. ONO Tsutomu, a Short-term Expert in Training System Development and Management. With extensive experience in E-Learning Platforms globally, he will address technical challenges and ensure sustainable ELP operations. Mr. ONO will provide on-site support in Cambodia three times through October, starting with his current month-long stay. Remote support from Japan will also continue throughout his assignment. We look forward to his expertise enhancing our training systems and project outcomes.

Ms. HIGASHI Hiromi, a Master of Public Health student at Nagasaki University, concluded her internship with the project on 30 January. During her internship, she supported several project-related tasks and participated in the INSET observations in BTB and KC. Through these activities, she gained practical experience in project coordination, documentation, and communication with multiple stakeholders, as well as a deeper understanding of project operations and international cooperation in the health sector. The project team wishes her continued success in her future studies and career.



### UPCOMING ACTIVITIES IN FEBRUARY :

- 2nd : Trainer meeting for Communication (Online)
- 3rd : Meeting with Trainers of Nursing Ethics
- 4th–5th : INSET in Srey Sentor OD, KC (Communication)
- 6th : Meeting with the KC PHD Director
- 10th : Monthly Meeting with JICA HQ / Cambodia Office (online)
- 10th : ELP Meeting with HRDD, IT Officers of MoH and PHD
- 11th–12th : INSET in Moung Russey OD, BTB (Quality Improvement and Patient Safety & Nursing Management and Leadership)
- 25th–26th : INSET in Bateay OD, KC (Basic Nursing Skills)

# MONTHLY REPORT

## VOLUME 49

## មករា ២០២៦


**CONTACT INFORMATION**

Email: info@jicastrings.com

Project Office:

- Ministry of Health (MoH)

Department of Human Resources Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- National Maternal and Child Health Center (NMCHC)

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage

## សកម្មភាពគម្រោងក្នុងខែមករា៖

- ថ្ងៃទី៨៖ កិច្ចប្រជុំគ្រូបណ្តុះបណ្តាលសម្រាប់មុខវិជ្ជា ការលើកកម្ពស់គុណភាព និង សុវត្ថិភាពអ្នកជំងឺ (តាមប្រពន្ធ័អនឡាយ)
- ថ្ងៃទី៩៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១៤ ដល់ទី១៥៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម វគ្គជំនាញមូលដ្ឋាន នៃការថែទាំ និងវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ
- ថ្ងៃទី២១ ដល់ទី២២៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម វគ្គការស្រាវជ្រាវផ្នែកថែទាំ
- ថ្ងៃទី២២៖ កិច្ចប្រជុំសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) ទូទាំងប្រទេស
- ថ្ងៃទី២៦៖ អ្នកជំនាញផ្នែក IT រយៈពេលខ្លីចូលរួមជាមួយគម្រោង
- ថ្ងៃទី២៧៖ កិច្ចប្រជុំ ជាមួយក្រុមការងារ HRDD IT អំពី ELP
- ថ្ងៃទី២៨ ដល់ទី២៩៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម វគ្គការប្រើប្រាស់ដំណើរការនៃការថែទាំជំងឺ និងវគ្គព័ត៌មានវិទ្យានៃការថែទាំ
- ថ្ងៃទី៣០៖ បញ្ចប់ការហាត់ការ (និស្សិត MPH មកពីសាកលវិទ្យាល័យ Nagasaki)

## ការពង្រីកការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) ទូទាំងប្រទេស៖ ប្រជុំស្វែងរកយុទ្ធសាស្ត្រសម្រាប់ការអនុវត្តវគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT)

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ ក្រសួងសុខាភិបាល តាមរយៈ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (HRDD) បានរៀបចំកិច្ចប្រជុំជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្តនៅទូទាំងប្រទេស ដើម្បីពិភាក្សាអំពីការពង្រីកវគ្គបណ្តុះបណ្តាល INSET នៅទូទាំង២៥ រាជធានី-ខេត្ត ក្រោមអធិបតីភាពឯកឧត្តមសាស្ត្រាចារ្យ ធា គ្រួយ រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល និងជានាយកគម្រោង។ សម័យប្រជុំនេះមានការអញ្ជើញចូលរួមពីអង្គភាពពាក់ព័ន្ធក្នុងទីស្តីការក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត ដោយមានក្រុមការងារគម្រោង STRINGS ចូលរួមជាអ្នកសង្កេតការណ៍ផងដែរដើម្បីបន្តអនុវត្តន៍ផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់ឆ្នាំ២០២៦។

ការប្រជុំផ្តោតសំខាន់លើការបណ្តុះបណ្តាលទូទាំងប្រទេស នៃការបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាលថ្នាក់ជាតិ (N-ToT) សម្រាប់វគ្គក្រមសីលធម៌នៃការថែទាំ ដែលត្រូវបានជ្រើសរើសជាពិសេសសម្រាប់ស្តង់ដារវិជ្ជាជីវៈ។ លោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងជាប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង បានគូសបញ្ជាក់អំពីយុទ្ធសាស្ត្រអនុវត្តដោយប្រើប្រាស់បទពិសោធន៍ពីខេត្តសាកល្បង។ ការបណ្តុះបណ្តាល (N-ToT) ត្រូវបានគ្រោងទុកជាបណ្តោះអាសន្ននៅចន្លោះខែមេសា ដល់ខែសីហា ឆ្នាំ២០២៦ នៅទូទាំងភូមិភាគទាំងបួន និងរាជធានីភ្នំពេញផងដែរ។ វគ្គបណ្តុះបណ្តាលទាំងនេះនឹងបង្កើតបានជាក្រុមគ្រូបង្គោលស្នូលដែលនឹងដឹកនាំវគ្គបន្តបន្ទាប់ទៀតនៅក្នុងខេត្តរបស់ពួកគេ ដើម្បីធានាបាននូវការថែទាំដោយផ្តោតលើអ្នកជំងឺ។

កិច្ចប្រជុំនេះ ទទួលបានការផ្លាស់ប្តូរប្រកបដោយផលិតភាព ដែលតំណាងខេត្តបាត់ដំបង និងខេត្តកំពង់ចាម បានចែករំលែកបទពិសោធន៍ពីការអនុវត្តការបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅក្នុងខេត្តរបស់ពួកគេ។អង្គប្រជុំបានគូសបញ្ជាក់ពីលក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់ការតែងតាំងគ្រូបណ្តុះបណ្តាលដែលមានការប្តេជ្ញាចិត្ត ដើម្បីធានាគុណភាពក្នុងការបណ្តុះបណ្តាល។ លើសពីនេះ អង្គប្រជុំក៏បានស្វែងយល់ពីនិរន្តរភាពនៃការបណ្តុះបណ្តាល ដោយផ្តោតលើភាពចាំបាច់សម្រាប់ខេត្តនីមួយៗក្នុងការបញ្ចូលវគ្គ INSET ទៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ខេត្ត ដើម្បីរក្សានិរន្តរភាពវគ្គបណ្តុះបណ្តាលបន្ទាប់ពីគម្រោងនេះបញ្ចប់។



Nursing Ethics Module



Meeting Participants

## ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) ឆ្នាំ២០២៦ ដំបូង ក្នុងខេត្តកំពង់ចាម៖ ការផ្តល់អំណាចដល់គ្រូបណ្តុះបណ្តាល និងសិក្ខាកាម

ដោយបន្តផែនការពីឆ្នាំមុនវគ្គ INSET ដំបូងសម្រាប់ឆ្នាំ២០២៦ ត្រូវបានដំណើរការដោយជោគជ័យនៅខេត្តកំពង់ចាម។ នៅថ្ងៃទី១៤ ដល់ទី១៥ ខែមករា កម្មវិធីនេះបានចាប់ផ្តើមដោយវគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ (QI & PS) ដែលមានសិក្ខាកាមចូលរួមចំនួន ៣០នាក់ និងវគ្គជំនាញមូលដ្ឋាននៃការថែទាំ (BNS) មានសិក្ខាកាមចូលរួមចំនួន៣១នាក់។ ឱកាសដ៏សំខាន់នេះមានការចូលរួមពីលោកសាស្ត្រាចារ្យជំ.កុយ វីយ៉ា អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល និងជាប្រធានក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (TMT) រួមជាមួយនឹងលោក ជា សុភក្ត្រមុនីរ័ត្ន ប្រធានក្រុមប្រឹក្សាភិបាលគណៈគិលានុបដ្ឋាកជាតិ ដែលអ្នកទាំងពីរមានតួនាទីជាអ្នកអភិបាល និងត្រួតពិនិត្យវគ្គ។

វគ្គបណ្តុះបណ្តាលនេះ បានចាប់ផ្តើមដោយមានការថ្លែងសុន្ទរកថាបើកពីប្រធានគណៈប្រតិភូទាំងពីររូប និងឯកឧត្តមវេជ្ជបណ្ឌិត គឹមស្វរ ភីរុណ ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម។ ឯកឧត្តម បានគូសបញ្ជាក់ពីសារៈប្រយោជន៍នៃវគ្គបណ្តុះបណ្តាលនេះ និងកំណត់ការរំពឹងទុកខ្ពស់សម្រាប់ការពង្រឹងជំនាញរបស់សិក្ខាកាមចូលរួម និងការពង្រឹងគុណភាពនៃការថែទាំ។ បន្ទាប់ អ្នកគ្រប់គ្រងបានសង្កេតមើលវគ្គ និងផ្តល់ធាតុចូលដ៏មានតម្លៃដល់ក្រុម PTMT គ្រូបណ្តុះបណ្តាល និងសិក្ខាកាម ដើម្បីកែលម្អការអនុវត្ត INSET បន្ថែមទៀត។ ពួកគេបានលើកទឹកចិត្តជាពិសេសដល់គ្រូបណ្តុះបណ្តាលឱ្យរក្សាការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការផ្តល់នូវការបង្រៀនប្រកបដោយគុណភាពខ្ពស់។ លើសពីនេះកិច្ចប្រជុំសម្របសម្រួលដែលធ្វើឡើងនៅថ្ងៃតែមួយ បានអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ បុគ្គលិកគម្រោង និងអ្នកតំណាងនៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ចែករំលែកលទ្ធផលនៃការត្រួតពិនិត្យ និងពិភាក្សាអំពីបញ្ហាប្រឈម និងការទទួលខុសត្រូវសម្រាប់ដំណាក់កាលខាងមុខ។

សប្តាហ៍បន្ទាប់វគ្គបណ្តុះបណ្តាលបានបន្តជាមួយនឹងវគ្គការស្រាវជ្រាវផ្នែកថែទាំ ដោយមានសិក្ខាកាមចូលរួមចំនួន ២២នាក់ នៅថ្ងៃទី២១ ដល់ទី២២ ខែមករា បន្ទាប់មកវគ្គព័ត៌មានវិទ្យានៃការថែទាំ មានសិក្ខាកាមចំនួន ២៣នាក់ និងនៅថ្ងៃទី២៨ ដល់ទី២៩ ខែមករា វគ្គការប្រើប្រាស់ដំណើរការនៃការថែទាំជំងឺ មានសិក្ខាកាមចំនួន ៣៣នាក់ចូលរួម។

នៅខែកុម្ភៈ ខាងមុខនេះ វគ្គសិក្សាជាច្រើនត្រូវបានកំណត់ពេលទូទាំងតំបន់ស្រុកប្រតិបត្តិការផ្សេងៗនៅខេត្តកំពង់ចាម (KC) និងខេត្តបាត់ដំបង (BTB)។ សកម្មភាពទាំងនេះត្រូវបានរំពឹងថានឹងគ្របដណ្តប់លើ២០% នៃសិក្ខាកាមក្នុងផែនការដែលនៅសេសសល់ រួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចបាននូវចំនួនគោលដៅបណ្តុះបណ្តាលរបស់គម្រោង។



Opening Session



BNS course



# MONTHLY REPORT

## VOLUME 49

## មករា ២០២៦


**CONTACT INFORMATION**

Email: info@jicastrings.com

Project Office:
- Ministry of Health (MoH)

Department of Human Resources Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh
- National Maternal and Child Health Center (NMCHC)

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

Scan here to find out more about us:
JICA's FB Page
Project's Homepage


## បេសកកម្មអ្នកជំនាញ៖ ជំរុញការពង្រឹង វេទិកា E-Learning

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ លោក **ONO Tsutomu** អ្នកជំនាញរយៈពេលខ្លីក្នុងការអភិវឌ្ឍន៍ប្រព័ន្ធបណ្តុះបណ្តាល និងការគ្រប់គ្រង បានចាប់ផ្តើមបេសកកម្មរយៈពេលមួយខែដំបូងរបស់គាត់នៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីការមកដល់របស់គាត់ គាត់បានចូលរួមយ៉ាងសកម្មជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីសម្រួលដល់វេទិកា **E-Learning (ELP)**។

ក្នុងសប្តាហ៍ដំបូងរបស់លោក **ONO** ដែលបានមកដល់កម្ពុជា គាត់បានធ្វើសកម្មភាពដូចខាងក្រោម៖

- <u>ការពិគ្រោះយោបល់ជាយុទ្ធសាស្ត្រជាមួយមន្ត្រីនៃHRDD</u>៖ នៅថ្ងៃទី២៧ ខែមករា លោកបានជួបជាមួយក្រុមមន្ត្រីIT នៃHRDD ដើម្បីពិនិត្យមើលផែនការការងារ និងពិភាក្សាអំពីផ្លូវឆ្ពោះទៅមុខសម្រាប់ **ELP** ។ កិច្ចប្រជុំតាមដានត្រូវបានកំណត់យកនៅថ្ងៃទី១០ ខែកុម្ភៈ ដើម្បីធ្វើការបង្ហាញពីជម្រើសប្រព័ន្ធសក្តានុពល ដែលនឹងជួយបញ្ជាក់ទិសដៅយុទ្ធសាស្ត្រសម្រាប់ការពង្រឹង **ELP** ។
- <u>ទស្សនកិច្ចដោយផ្ទាល់នៅខេត្តកំពង់ចាម</u>៖ នៅថ្ងៃទី២៨ ខែមករា គាត់បានសង្កេតមើលវគ្គព័ត៌មានវិទ្យានៃការថែទាំ នៅ **KC** ។ ដំណើរទស្សនកិច្ចនេះបានអនុញ្ញាតឱ្យមានការសន្ទនាដោយផ្ទាល់ជាមួយក្រុម **PTMT** និងអ្នកបច្ចេកទេសផ្នែកព័ត៌មានវិទ្យាទាក់ទងនឹងតម្រូវការប្រតិបត្តិការនៅនឹងកន្លែង។
- <u>ការចែករំលែកចំណេះដឹងជាមួយមន្ត្រីនៃ **NMCHC**</u>៖ នៅថ្ងៃទី៣០ ខែមករា លោកបានពិគ្រោះយោបល់ជាមួយមន្ត្រីព័ត៌មានវិទ្យា នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (**NMCHC**) ដោយទទួលបានការយល់ដឹងដ៏មានតម្លៃពីប្រតិបត្តិការ **ELP** ដែលមានស្រាប់របស់ពួកគេជាគោលសម្រាប់គម្រោង។

ត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ លោក **ONO** បានបង្ហាញការយល់ដឹងយ៉ាងច្បាស់អំពីបញ្ហាស្នូលរបស់ **ELP** ។ តាមរយៈការសំយោគព័ត៌មាន ការទស្សនកិច្ចដោយផ្ទាល់ និងការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធ គាត់កំពុងធានាឱ្យមានការផ្លាស់ប្តូរយ៉ាងរលូនពីការវាយតម្លៃទៅការអនុវត្ត។ បេសកកម្មដំបូងរបស់លោកនឹងបន្តរហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ហើយយើងមានទំនុកចិត្តថាជំនាញរបស់គាត់នឹងជួយពង្រឹងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលរបស់យើងបានយ៉ាងល្អប្រសើរ។



Meeting with HRDD IT team



Training Observation in KC

## ស្វាគមន៍អ្នកជំនាញការថ្មី និង កម្មវិធីលាគ្នាជាមួយអ្នក ហាត់ការ



យើងមានសេចក្តីសោមនស្សរីករាយក្នុងការស្វាគមន៍លោក **ONO Tsutomu** ដែលជាអ្នកជំនាញរយៈពេលខ្លីក្នុងការអភិវឌ្ឍន៍ និងការគ្រប់គ្រងប្រព័ន្ធបណ្តុះបណ្តាល។ ជាមួយនឹងបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងវេទិកា **E-Learning** ជាសកល លោកនឹងដោះស្រាយបញ្ហាប្រឈមបច្ចេកទេស និងធានាបាននូវប្រតិបត្តិការ **ELP** ប្រកបដោយនិរន្តរភាព។

លោក **ONO** នឹងផ្តល់ការគាំទ្រនៅនឹងកន្លែងក្នុងប្រទេសកម្ពុជាចំនួនបីលើក រហូតដល់ខែតុលា ដោយបច្ចុប្បន្នចាប់ផ្តើមជាមួយនឹងការស្នាក់នៅរយៈពេលមួយខែរបស់គាត់។ ការគាំទ្រពីចម្ងាយពីប្រទេសជប៉ុនក៏នឹងបន្តពេញមួយកិច្ចការរបស់គាត់ផងដែរ។ យើងទន្ទឹងរង់ចាំជំនាញរបស់គាត់ ក្នុងការពង្រឹងប្រព័ន្ធបណ្តុះបណ្តាល និងលទ្ធផលរបស់គម្រោង។

កញ្ញា **HIGASHI Hiromi** និស្សិតអនុបណ្ឌិតផ្នែកសុខភាពសាធារណៈនៅសាកលវិទ្យាល័យ **Nagasaki** បានបញ្ចប់ការហាត់ការជាមួយគម្រោងនៅថ្ងៃទី៣០ ខែមករា។ ក្នុងអំឡុងពេលហាត់ការ កញ្ញាបានជួយគាំទ្រកិច្ចការដែលទាក់ទងនឹងគម្រោងជាច្រើន ហើយបានចូលរួមក្នុងការសង្កេត **INSET** នៅខេត្ត **BTB** និង **KC** ។ តាមរយៈសកម្មភាពទាំងនេះ គាត់ទទួលបានបទពិសោធន៍ជាក់ស្តែងក្នុងការសម្របសម្រួលគម្រោង ការរៀបចំឯកសារ និងការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធជាច្រើន ក៏ដូចជា ការយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រតិបត្តិការរបស់គម្រោង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យសុខាភិបាល។ បុគ្គលិកការងារគម្រោងសូមជូនពរកញ្ញាបន្តទទួលបានជោគជ័យក្នុងការសិក្សា និងអាជីពរបស់គាត់នាពេលអនាគត។



## សកម្មភាពនាពេលខាងមុខក្នុងខែកុម្ភៈ ៖

- ថ្ងៃទី២៖ កិច្ចប្រជុំគ្រូបណ្តុះបណ្តាលសម្រាប់មុខវិជ្ជា ការប្រាស្រ័យទាក់ទង (តាមប្រពន្ធ័អនឡាយ)
- ថ្ងៃទី៣៖ កិច្ចប្រជុំគ្រូបណ្តុះបណ្តាលនៃមុខវិជ្ជា សីលធម៌ នៃការថែទាំ
- ថ្ងៃទី៤ ដល់ទី៥៖ ការបណ្តុះបណ្តាល INSET នៅស្រុកប្រតិបត្តិស្រីសន្ធរ ក្នុងខេត្តកំពង់ចាម វគ្គ ការប្រាស្រ័យទាក់ទង
- ថ្ងៃទី៦៖ កិច្ចប្រជុំជាមួយប្រធានមន្ទីរនៃរដ្ឋបាលខេត្តកំពង់ចាម
- ថ្ងៃទី១០៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១០៖ កិច្ចប្រជុំជាមួយមន្ត្រីនៃ HRDD មន្ត្រីព័ត៌មានវិទ្យានៃ MoH និងPHD
- ថ្ងៃទី១១ ដល់ទី១២៖ ការបណ្តុះបណ្តាល INSET នៅស្រុកប្រតិបត្តិមោងឬស្សី ក្នុងខេត្តបាត់ដំបង វគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ និងវគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ
- ថ្ងៃទី២៥ ដល់ទី២៦៖ ការបណ្តុះបណ្តាល INSET នៅស្រុកប្រតិបត្តិបាធាយ ក្នុងខេត្តកំពង់ចាម វគ្គ ជំនាញមូលដ្ឋាន នៃការថែទាំ